# ការចិញ្ចឹមជន្លេនក្រហមជាចំណីមាន់-ទា

## ព័ត៌មានទូទៅ

ជន្លេនគឺជាសត្វម្យ៉ាង ដែលមានប្រយោជន៍ច្រើន មុខចំពោះការងារចិញ្ចឹមសត្វ និងការដាំដំណាំផ្សេងៗ។

ជន្លេនជាសត្វងាយស្រួលចិញ្ចឹម សំបូរទៅដោយប្រូតេអ៊ីនខ្ពស់ ជាចំណីសំរាប់សត្វមាន់ ទា ជ្រូក ត្រី និង កង្កែបជាដើម។

## ការជ្រើសរើសទីតាំងសំរាប់ជីករណ្តៅ



- កន្លែងមានដីខ្ពស់ល្មម មិនលិចទឹក មិនក្តៅស្ងួតខ្លាំង
- ដីមានម្លប់ត្រជាក់ និងខ្យល់ចេញចូលបានល្អ

## ២. ការរៀបចំរណ្តៅចិញ្ចឹមជន្លេន

ទំហំរណ្តៅដែលសមស្របមាន:

- បណ្តោយប្រវែង២ម ទទឹង១ម និង ជំរៅ០,៣ម។



- ត្រូវទ្រាប់ក្រណាត់ប្លាស្ទិកនៅបាតរណ្តៅ
- បាំងបន្ទះក្តារជុំវិញជៀសវាងដីបាក់ចូលក្នុងរណ្តៅ
- ទំលុះរន្ធតូចៗ ចំងាយពីគ្នា ១សង់ទីម៉ែត្រ។

## ៣. ការផ្តល់ចំណីអោយជន្លេន

ចំណីសំរាប់ដាក់អោយជន្លេនស៊ីមាន: លាមកគោ លាមកសេះ ពពែស្រស់ និងកាកសំណល់ផ្ទះបាយ។

- ដំបូងត្រូវដាក់ដីទ្រាប់បាត កំរាស់ ៥សង់ទីម៉ែត្រ។ រួចកៀរអោយស្មើមុននឹងដាក់លាមកគោស្រស់ចូល។
- ប្រើលាមកគោស្រស់ ចំនួន ១០០គ.ក ដោយបំបែក អោយម៉ត់មានកំរាស់ ១០សង់ទីម៉ែត្រ។

## ៤. ការដាក់លាមកគោស្រស់និងពូជជន្លេនសំរាប់ចិញ្ចឹម

- នៅពេលដាក់លាមកគោរួច ត្រូវយកពូជជន្លេន ដាក់ក្នុងលាមកគោនោះចំនួន៤-៥កន្លែង។
- ពូជជន្លេនត្រូវប្រើមានចំនួន១គីឡូក្រាម (គិតទាំងជន្លេន និងលាមកសត្វ) ក្នុងផ្ទៃរណ្តៅ ១ម៉ែត្រការ៉េ។



- បន្ទាប់ពីដាក់ពូជជន្លេនហើយ ត្រូវស្រោចទឹកអោយសើមល្មម ជៀសវាងកុំអោយទឹកជោគពេក។



- ស្រោចទឹក ២-៣ថ្ងៃម្តង ដើម្បីរក្សាសំណើមអោយបានថេរ តែមិនត្រូវស្រោចទឹកអោយជោគពេកទេ។
- នៅពេលជន្លេនកកើតបានច្រើន ត្រូវបន្ថែមលាមកគោស្រស់ ចំនួន៣គីឡូក្រាមក្នុង១ម៉ែត្រការ៉េ ក្នុងរយៈពេល ១សប្តាហ៍ម្តង។

### ៥. ការរៀបចំដំបូលរណ្តៅចិញ្ចឹមជន្លេន

- ធ្វើដំបូលដើម្បីការពារទឹកភ្លៀង និងកំដៅថ្ងៃ
- ធ្វើរបងព័ទ្ធជុំវិញ ដើម្បីការពារសត្វចូលកកាយ។



### ៦. ការប្រមូលផលជន្លេនអោយសត្វស៊ី

ត្រូវយកតាមកន្លែងបន្តបន្ទាប់។ ឧទាហរណ៍ បើយកទំហំ ១០ សង់ទីម៉ែត្រ ត្រូវដាក់លាមកគោស្រស់ នៅកន្លែងនោះ ចំនួន២គីឡូក្រាម។ ពេលយកអស់តាមលំដាប់ដល់កន្លែង ដើម នោះជន្លេនកកើតមានដូចដើមវិញ។



### ៧. សន្និដ្ឋាន

ការចិញ្ចឹមជន្លេនមានប្រយោជន៍សំខាន់ណាស់ សំរាប់ជា ចំណីសត្វផង និងលាមករបស់វាធ្វើជាជីធម្មជាតិសំរាប់ដាំដំណាំដ៏ល្អបំផុត ជាហេតុធ្វើអោយដំណាំលូតលាស់បានល្អ និង បង្កើនទិន្នផលខ្ពស់។


រៀបចំដោយ

នាយកដ្ឋានផ្សព្វផ្សាយកសិកម្មនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

ឧបត្ថម្ភថវិកាដោយអង្គការស្បៀង និងកសិកម្ម នៃ សហប្រជាជាតិ (FAO)

ទំនាក់ទំនងទូរស័ព្ទ: ០២៣ ២១៥ ៨១៩


# ការចិញ្ចឹមជន្លេនក្រហម ជាចំណីមាន់-ទា




កម្មវិធីសម្រាប់សន្តិសុខស្បៀង និង កាត់បន្ថយភាពក្រីក្រ (FSPR)

ឆ្នាំ ២០០៨